ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

********

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ល.ក/លេខ ០៧.០៥៦/១៣ គ.ជ.ប.អគ្គ.ពស

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៣

# អាជ្ញាធរបោះឆ្នោតនៃប្រទេសអាស៊ានចូលរួមសង្កេតការណ៍បោះឆ្នោតនៅកម្ពុជា

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានអញ្ជើញអាជ្ញាធររៀបចំការបោះឆ្នោតនៃប្រទេសអាស៊ាន អគ្គលេខាធិការដ្ឋានអាស៊ាន ប្រទេសឥណ្ឌា និងសមាគមនៃអាជ្ញាធររៀបចំការបោះឆ្នោតអាស៊ី [Association of Asian Election Authorities (AAEA-REPUBLIC OF KOREA)] ដើម្បីចូលរួមសង្កេតមើលពីដំណើរការបោះឆ្នោត នាថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ ។

ជាការឆ្លើយតបមានប្រទេសដូចខាងក្រោមអញ្ជើញចូលរួម ៖

- ប្រទេស ម៉ាឡេស៊ី អ្នកចូលរួមចំនួន ០២ រូប
- ប្រទេស មីយ៉ាន់ម៉ារ អ្នកចូលរួមចំនួន ០២ រូប
- ប្រទេស ហ្វីលីពីន អ្នកចូលរួមចំនួន ០៣ រូប
- ប្រទេស ថៃឡង់ អ្នកចូលរួមចំនួន ០៦ រូប
- ប្រទេស ឡាវ អ្នកចូលរួមចំនួន ០២ រូប
- ប្រទេស ឥណ្ឌា អ្នកចូលរួមចំនួន ០១ រូប
- អគ្គលេខាធិការដ្ឋានអាស៊ាន អ្នកចូលរួមចំនួន ០២ រូប
- AAEA-REPUBLIC OF KOREA អ្នកចូលរួមចំនួន ០៥ រូប ៕